# រឿងមិនចង់ភ្លេច

រឿងខ្ញុំចង់ចាំ កន្លងយូរឆ្នាំ ចិត្តចាំជាក់ស្បាន់
ពិដោរស្រទន់ គន្ធផ្កាក្រវាន់ ខ្ញុំធ្លាប់បេះកាន់
លេងឯក្បែរស្ទឹង។

យូរឆ្នាំទៅហើយ ដួងចិត្តឥតស្បើយ នៅឡើយចង់ដឹង
ចង់ស្គាល់ម្ដងទៀត ជាតិក្រវាន់ហ្នឹង នាសាខំប្រឹង
រំពឹងក្លិនផ្កា។

ស្រូបស្រង់ម្ដេចក្ដី ក្លិនលើផែនដី មានច្រើនប្រការ
ពុំគាប់ពុំដូច ចិត្តដូចប្រាថ្នា ក្រវាន់បុស្បា
ផ្កាដុះជាយព្រៃ។

រឿងមួយទៀតនោះ ចាំមិនភ្លេចសោះ ទោះយូរហើយក្ដី
ថ្ងៃមួយខ្ញុំបាន ក្បែរមក្សាន្តហរទ័យ ព្រោះពើបចំណី
ឆ្ងាញ់ក្រៃប្រមាណ។

នឹកនំបញ្ចុក សម្លប្រហុក បានតែមួយចាន
ញ៉ាំមួយភ្លែតអស់ នៅស្រណោះឃ្លាន ធ្វើម្ដេចនឹងបាន
មួយចានថ្មីទៀត។

ច្រើនឆ្នាំកន្លង ខ្ញុំដើរអស់ផង កន្ទុកកន្ទៀត
សាកនំបញ្ចុក ច្រើនស្រុកច្រើនស្មៀត ពុំយល់រសជាតិ
ដូចចិត្តបៀតប៉ង។

នេះឬរឿងមនុស្ស បើចង់ជួបហួស បែរជ្រួសបំណង
តែបើចង់ភ្លេច ខំគេចកន្លង បែរជាពាររង
ម្ដងហើយម្ដងទៀត៕

ម៉ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី

